ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានតំណាងកម្ពុជានៅម៉ាឡេស៊ី និងចិន អន្តរាគមជួយពលរដ្ឋខ្មែរ៦នាក់

------------

I. ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**៥នាក់** ដូចខាងក្រោមៈ

(១) ពលករ**ឡ.រ** អាយុ២៩ឆ្នាំ និង(២) ពលការិនី **ក.ស.រ** អាយុ២២ឆ្នាំ ដែលជាប្ដីប្រពន្ធនឹងគ្នា មកពីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ត្រូវបានមេខ្យល់នាំធ្វើដំណើរតាមរថយន្តកាត់តាមប្រទេសថៃទៅកាន់ម៉ាឡេស៊ី ធ្វើការនៅតាមរោងចក្រ កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ ដោយចង់ត្រឡប់មកកម្ពុជាវិញ អ្នកទាំងពីរបានស្នើសុំកិច្ចអន្តរាគមន៍ពីស្ថានទូតនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ផ្ដល់កន្លែងស្នាក់នៅ និងអាហារបរិភោគជូនអ្នកទាំងពីរ ហើយពួកគេបានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៧ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង**០៧:៣៥**នាទីព្រឹក តាមជើងយន្តហោះ AK536 ។

(៣) ពលករ **ផ.ស.ភ** អាយុ៣១ឆ្នាំ មកពីស្រុកបវេល ខេត្តបាត់ដំបង

(៤) ពលករ **ទ.រ.ថ** អាយុ២៥ឆ្នាំ មកពីស្រុកបាទី ខេត្តតាកែវ

(៥) ពលករ **អ.ច.រ** អាយុ២៨ឆ្នាំ មកពីស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ពលករទាំង៣នាក់ ត្រូវបានមេខ្យល់នាំទៅធ្វើការលើទូកនេសាទថៃ កាលពីឆ្នាំ២០០៣។ ដោយធ្វើការលំបាកខ្លាំង បរិភោគមិនគ្រប់គ្រាន់ ហើយត្រូវបានថៅកែធ្វើបាបថែមទៀតនោះ អ្នកទាំង៣បានគៀសខ្លួនចេញពីទូក រួចទៅរស់នៅនិងធ្វើការបន្តនៅរដ្ឋ Sarawak ប្រទេសម៉ាឡេស៊ី។ ដោយរស់នៅខុសច្បាប់ ហើយបារម្ភខ្លាចអាជ្ញាធរម៉ាឡេស៊ីចាប់ខ្លួនផងនោះ ពលករទាំង៣នាក់ បានទាក់ទងទៅក្រុមគ្រួសារដើម្បីជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោយពីមានសំណើអន្តរាគមន៍ពីក្រុមគ្រួសាររបស់ពលករ ស្ថានទូតបានទាក់ទងជួបពលករទាំង៣នាក់ និងបានចេញលិខិតធ្វើដំណើរជូនពួកគេ ព្រមទាំងបានសម្របសម្រួលជាច្រើនលើកច្រើនសារជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ីនៅរដ្ឋ Sarawak។

ពលករទាំង៣នាក់ខាងលើ នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៧ ខែមេសា ឆ្នាំ២០១៧** វេលាម៉ោង **១៧:៣៥** នាទី តាមជើងយន្តហោះ MH 2715 ។

II.  ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងក្វាងចូវ ប្រទេស**ចិន** បានអន្តរាគមជួយស្ត្រីខ្មែរម្នាក់ឈ្មោះ **ព.ស.ម** អាយុ២៤ឆ្នាំ មកពីស្រុកស្អាង ខេត្តកណ្តាល ដែលរងគ្រោះដោយការជួញដូរ។ នាងត្រូវបានមេខ្យល់បោកបញ្ឆោតនាំធ្វើដំណើរកាត់តាមប្រទេសវៀតណាម ចូលទៅប្រទេសចិនដោយខុសច្បាប់ ហើយបានរៀបការជាមួយបុរសជនជាតិចិននៅខេត្តហូណាន កាលពីថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦។ នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ នាងបានស្នើសុំស្ថានអគ្គកុងស៊ុល ជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ស្ត្រីរងគ្រោះ បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៦** ខែ**មេសា** ឆ្នាំ**២០១៧** វេលាម៉ោង**១៥:៣០**នាទីរសៀល តាមជើងយន្តហោះK6669 ៕

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ